# ការសំភាសន៏របស់អ៊ុំស្រី ម៉ៅ ផល្លី ( សុភី )

ក ៖ អ្នកសំភាសន៏មាន អ៊ុំ កន្និកា     ខ ៖ អ្នកដែលត្រូវគេសំភាសន៏ ម៉ៅ ផល្លី ( សុភី )

ក៖

ជំរាបសួរអ្នកមីង....ចាំហើយជាដំបូងសូមថ្លែងអំណរគុណដល់អ្នកមីងដែលបានអនុញ្ញាតអោយនាងខ្ញុំធ្វើការសំភាសន៏អ្នកមីងទាក់ទងទៅនិងជីវប្រវត្តិផ្ទាល់ខ្លួនរបស់អ្នកមីងផងដែរ។

ហើយការសំភាសន៏មួយនេះគឺធ្វើឡើងដោយសាលាសកលវិទ្យាល័យ"ប៊ីវ៉ាយយូ"(BYU)...ដោយសារតែសាលាសកលវិទ្យាល័យរបស់ពួកយើងមានបំណងចង់ថែរក្សានូវជីវប្រវត្តិរបស់អ្នកមីងដើម្បីទុកសំរាប់កូនចៅអ្នកមីងជំនាន់ក្រោយដើម្បីអាចអោយពួកគេបានស្តាប់លឺទទួលដឹងទទួលស្គាល់ថាអ្នកមីងបានឆ្លងកាត់នូវទុក្ខលំបាកទាំងអស់នោះហើយពួកគេអាចទុកការលំបាកទាំងអស់នោះទុកជាទុនមួយដើម្បីដឹងនាំជីវិតរបស់គេផងដែរ។

ហើយបន្ទាប់ពីការបញ្ចប់នូវការថតសំលេងនិងក៏ដូចជាការសំភាសន៏មួយនេះពួកយើងសុំការអនុញ្ញាតពីអ្នកមីងដើម្បីដាក់សំលេងរបស់អ្នកមីងចូលទៅក្នុងគេហទំព័ររបស់ពួកយើងដែលមានឈ្មោះថា www.cambodia.noralhistory@by.edu

ផងដែរហើយខ្ញុំជាអ្នកសំភាសន៏មានឈ្មោះថា អ៊ុំ កន្និកា

ហើយកាលបរិច្ឆេតគឺនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨

ហើយទីកន្លែងគឺនៅភូមិចុងឃ្មៀសផងដែរហើយយើងនិងទៅជួបគាត់ទាំងអស់គ្នា។ជំរាបសួរអ្នកមីង......!

ខ៖ ចាំ...លើកដៃថ្វាយព្រះ.....!

ក៖ តើអ្នកមីងមានឈ្មោះអ្វីដែរ?

ខ៖ ម៉ៅ ផល្លី.....

ក៖ ម៉ៅ ផល្លី.....!

ខ៖ ចាំ......ម៉ៅ ផល្លី.....!

ក៖ ចាំ.....ចុះអ្នកមីងដូចជាមានឈ្មោះហៅក្រៅអីទេ? ដូចថាគេតែងហៅ?

ខ៖ មាន.....!

ក៖ ហៅថាមេចទៅ?

ខ៖ ហៅ សុភី...

ក៖ គេហៅ សុភី.....

ខ៖ ចាំ......

ក៖ ឈ្មោះនេះតៀអ្នកណាអ្នកផ្ដើមហៅដំបូងគេអ្នកមីង?

ខ៖ ឈ្មោះកំណើតឈ្មោះញ៉ុមឈ្មោះ ភី......

ក៖ ឈ្មោះ ភី តែម្ដង.....

ខ៖
ដល់តែពេលនិងគេកែឈ្មោះគេហៅញ៉ុមផល្លីៗទៅក៏ក្នុងអត្តសញ្ញាណប័ត្រនិងដាក់ឈ្មោះ ម៉ៅ ផល្លី និងរហូតមកបណ្ដោយនិង......

ក៖
ចាំ...ចុះតើអ្នកមីងមានឈ្មោះហៅក្រៅផ្សេងទៀតដែលគេដាក់រហ័សនាមពីក្មេងអីមានទេ?

ខ៖ អត់មានទេកូន.....មានតែមួយប៉ិននេះឯង។

ក៖
អត់មានទេ....ចាំចុះដូចជាអាយុរបស់អ្នកមីងវិញតើអ្នកមីងមានអាយុប៉ុន្មានហើយអ្នកមីង?

ខ៖ ហាសិបប្រាំបី.....

ក៖ អ៎...ហាសិបប្រាំបីឆ្នាំហើយ។
ចុះតើអ្នកមីងចាំទេថាអ្នកមីងកើតនៅក្នុងថ្ងៃខែឆ្នាំណាដែរ?

ខ៖ ទាល់តែមើលអត្តសញ្ញាណប័ត្រអូន.....

ក៖ អូចាំ...អញ្ចឹងឆ្នាំអ្នកមីងអត់ចាំដែរណោះអ្នកមីងណោះ?

ខ៖ ឆ្នាំចាំ......

ក៖ ឆ្នាំអីគេទៅអ្នកមីង?

ខ៖ ឆ្នាំ ខាល......

ក៖ ឆ្នាំខាលណោះ?

ខ៖ និងឯង......!
ឆ្នាំខាលឆ្នាំកើតហើយបើថ្ងៃកំណើតវិញថ្ងៃអង្គារ៍...អឹក....ឆ្នាំមួយពាន់ប្រាំបួនរយហុកសិបមួយ។

ក៖ អូចាំ.....ពាន់ប្រាំបួនរយហុកសិបមួយ!

ខ៖ ចាំ........!

ក៖ ចុះដូចជាទីកន្លែងកំណើតវិញតើអ្នកមីងកើតនៅទីណាដែលអ្នកមីង?

ខ៖ អូ.....កើតនៅឆ្ងាយណាស់កូន....! កើតនៅបាត់ដំបងអ្នក.....!

ក៖ អូ្ន......អ្នកមីងកើតនៅខាងបាត់ដំបងវិញ?

ខ៖ ចាំ......!

ក៖ ម្តុំនោះគេហៅម្តុំភូមិស្រុកអីគេដែរ?

ខ៖
អឺ.....កើតនៅបាត់ដំបងស្រុកមង្គលសិរីសព្វថ្ងៃគេប្រែឈ្មោះអីខ្ញុំអត់ដឹងទេតែញ៉ុមចេញម៉ោយូរហើយតាំងពីចិតសិបប្រាំបួនចេញពីស្រុកពីចិតសិបប្រាំបួនម៉ោនៅភូមិប្លួនមុខស្រុកមង្គលសិរីខេត្តបាត់ដំបង...!

ក៖ អ៎.....ចាំតែឥលូវគេកែយ៉ាងមិចទៀតអ្នកមីងអត់ដឹងទេ?

ខ៖ ចា៎.....អត់ដឹងទេ!

ក៖ ចា៎....តែពីដើមមិញគេហៅអញ្ចោះឯង។

ខ៖ ពីសង្គមចាស់មិញគេហៅអញ្ចឹងឯង!

ក៖ អ៎..ចា៎...អញ្ចឹង...!

ខ៖ តែខ្ញុំចេញពីស្រុកយូរហើយតាំងពីចិតសិបប្រាំបួនមកម្លេះ!

ក៖ កាលអាពតអ្នកជំលៀសនិងម្លោះអុំណោះ?

ក៖
ចេញម៉ោតាំងពីជំនាន់អាពតជំនាន់យួនរហូតញ៉ុមទៅដល់ជាយដែនខាវអាដាងអីឯណារិទ្ធិសែនរិទ្ធអីឯណាខ្ញុំដើររបូត។

ក៖
ចា៎...អញ្ចឹងកាលបែកម៉ោពីចិតសិបប្រាំបួនមកដំបូងតើអ្នកមីងទៅរស់នៅទីកន្លែងណាដែរ?

ខ៖ ផ្ទះសៀមរាបនិងឯង។

ក៖ ដែលចេញពីចិតសិបប្រាំបួននិងម៉ោអុំមកនៅសៀមរាបតែម្តង?

ខ៖ ចា៎...! ឆ្នាំកៅសិបបីបងខ្ញុំទៅយកបងញ៉ុមទៅយកមកសៀបរាមមកនៅនេះឯង.!

កៈ ចាំទាល់តែកៅសិបបីបានអុំចេញមកសៀមរាបណោះ?

ខៈ ចាំ..គេដឹកម៉ោគេដឹកឆ្នាំកៅសិបបី។

កៈ អញ្ចឹងចិតសិបប្រាំបួននៅណោះនៅឡើយទេ?

ខៈ ចិតសិបប្រាំបួនខ្ញុំនៅឯណោះទេ....!

កៈ នៅខាងណាដែរ?

ខៈ នៅភ្នំដងរែក.....!

កៈ អុំ....នៅឯខាងភ្នំដងរែកវិញ អញ្ចឹងដំបូងឡើយនៅភ្នំដងរែកសិន?

ខៈ អត់ទេបើគិតពីចិតសិបប្រាំបួនវិញបើរាប់រៀបច្រើនណាស់កូន....!

កៈ អញ្ចឹងម្អោះ?

ខៈ បើរៀបរាប់វិញទៅនៅតាំងពីអូរបីជាន់អន្លង់ច័ន្ទ រិទ្ធិសែន
ខៅដាងចាស់ខៅដានថ្មីបើរៀបរាប់រៀបអត់អោះទេ!

កៈ អ្នកមីងប្តូរកន្លែងរហូត?

ខៈ
ប្តូររហូតចុះបើគេដឹងចុះគេវ៉ៃម្អោះគេវ៉ៃយើងអង្កាលពីចិតសិបប្រាំបួនរួចពីអាពតនោះគេវ៉ៃរហូតដល់គេវ៉ៃរហូតអញ្ចឹងទៅមីងនេះក៏តាមគេរហូតតាមទៅដល់ពេលឆ្នាំកៅសិបបីនិងគេដឹកមីងគេដឹកមីងនិងមុនដំបូងថាទៅនៅអីបាត់ដំបងទេដល់តាពេលចេញពីនិងទៅបងញ៉ុមបងប្រុសញ៉ុមនិងយកមកនៅសៀមរាបយើងនិងនាគគាត់ថាអូនអើយម៉ោនៅសៀមរាបម៉ោបានអង្គរកន្លះគីឡូក៏យើងអាចចិញ្ចឹមជីវិតយើងបានដែរព្រោះអូនឯងមានប្តីម្អោះ! ក៏ម៉ោបងប្រុសញ៉ុមនៅឯចុងស្រុកនិងក៏នាំញ៉ុមម៉ោនិងឯង។

កៈ ចាំ...អុំ..ចាំ!

ខ៖ ដល់ពេលនាំមកបានរស់នៅហើយយូរទៅប្ដីខ្ញុំក៏ស្លាប់...ប្ដីដើមខ្ញុំស្លាប់..!

ក៖ គាត់ឈ្មោះអីគេដែរ?

ខ៖ គាត់ឈ្មោះ រ៉ែត....ប្ដីដើមញ៉ុម...

ក៖ ប្ដីដើមអ៊ុំឈ្មោះរ៉ែត...តើគាត់ស្លាប់ដោយសារអីគេដែរអ៊ុំ?

ខ៖ គាត់ស្លាប់ធ្វើទាហ៊ាន...

ក៖ អ៎...ចាំគាត់ស្លាប់ហើយមិចទៀតទៅអ៊ុំ?

ខ៖
ដល់ពេលស្លាប់ធ្វើទាហ៊ានទៅដល់ពេលនិងទៅដល់ពេលញ៉ុមនេះម៉ែឪញ៉ុមនេះប្ដីញ៉ុមនេះឃើញញ៉ុមប្ដីញ៉ុមដែររាល់ថ្ងៃនេះគាត់បានប្រពន្ធរាលតែថ្ងៃនិងណាស់គាត់ក៏ចូលស្ដីរញ៉ុមទៅក៏បានកូនប្រាំប្រាំមួយទៅក៏ងាប់អស់បួននាក់ទៅនៅសល់កូនពីរនាក់តែទាំងអស់កូនញ៉ុមវាដប់ពីរនាក់ហើយងងាប់អស់បួនហើយអាពីក្រោយទៀតងាប់អស់ពីរទៀតទាំងអស់ងាប់អស់ប្រាំមួយនៅសល់តែកូនប្រាំមួយនាក់ទេ រាល់ថ្ងៃខ្ញុំចិញ្ចឹមកូនរបូត
បេះត្រកួនដកព្រលិត
បេះផ្កាឈូកអីយកទៅលក់គេជិះកង់ឯងទូលទៅយកទៅលក់ដល់ផ្សារលើទៅ..ដើររបូត

ក៖ ចាំ....បេះពីណាទៅណាដែរ?

ខ៖ បេះយើង..នៅធីក្វមនេះ ធីក្វមចុងឃ្លៀសយើងនេះញ៉ុមអត់មានកង់ជិះទេញ៉ុមទូលញ៉ុមទូលទៅដល់ចុងស្រុកទៅដល់យើងពីចុងស្រុកនិងទៅដល់យើងងើបពីម៉ោងពីរយប់ក៏ទូលទៅដល់ផ្សារលើ....

ក៖ ផ្សារលើតទៀត...!

ខ៖
ទូល......ម៉ោវិញដើរម៉ោវិញទៀតដើតពីផ្ការលើនិងអ្នាសដើរពីផ្សារលើមកដល់ចុងស្រុកទៀត...អត់ទាន់មានកង់ជិះទេ!

កៈ ដើររហូត......!

ខៈ
ដើររបូតកូនដើរទាំងទៅទាំងម៉ោដើរ...រហូតដល់ញុំមនិងទិញកង់គេបានមួយអាកង់កញ្ជាស់អញ្ចេះឯង
ដល់ពេលបានមួយនិងម៉ោក៏ញុំមបានអន្ទីតៗចិញ្ចឹមកូនដប់ពីរនាក់និងទៅនោះ
វេទនាចិញ្ចឹមកូនរបូត។

កៈ ចាំ...ចុះស្វាមីក្រោយរបស់អ្នកមីងគាត់មានឈ្មោះអីដែរ?

ខៈ ឈ្មោះ ខុន...!

កៈ ខុន...តែគាត់បែកពីអ្នកមីងនិងយូរឆ្នាំនៅ?

ខៈ បែកយូរហើយបែកមីងតាំងពីមីងមានអាយុសាមសិបប្រាំឆ្នាំមកម្លេះ
ហើយនែកឈ្មោះខុននិងដល់ពេលគេហៅរាល់ថ្ងៃនិងគេហៅថាសិទ្ធចាំ...ជាសិដ្ឋ.....

កៈ តែគាត់បានប្រពន្ធក្រោយទៀតហើយ!

ខៈ ចាំ....ប្រពន្ធក្រោយនិងឈ្មោះមីកាផល...

កៈ ឈ្មោះ ផល...

ខៈ ឈ្មោះផល
ចាំ..នៅចុងតន្ទតេសមិនដឹងនៅឯណាតេសការពីដើមមិញយាយប្រាប់ញុំមថានៅចង្រែងតែដល់ពេលគាត់សព្វថ្ងៃមិនដឹងថាគាត់នៅឯណាទេ!
ញុំមក៏សកវែងរកគាត់ដែរប៊ិនតែថាគាត់មានប្រពន្ធមានកូនមានក្មួយតែមីងចិត្តអត់ដាច់ប៊ិនដែរថាគាត់មានក៏មានទៅអត់គិតទៀតទេសព្វថ្ងៃមីងឈប់គិតទៀតហើយព្រោះគេគេមានប្រពន្ធមានកូនតទៅទៀតអោយគេមានសេចក្ដីសុខចំពោះគ្នាទៅចោះ!

កៈ
តែគាត់បានក្បត់អ្នកមីងទៅរកថ្មីឬក៏គាត់បានសុំអ្នកមីងលែងលះគ្នាសិនហើយបានគាត់ទៅឬក៏យ៉ាងមិច?

ខៈ គាត់បានគ្នានិងកាលនិងមីងកើតកូនមីពៅគេនិងនៅនិងពេទ្យគាត់ក្បត់ចិត្តមីង ក្បត់ចិត្តមីងដល់ពេលក្បត់ទៅមីងមានអ្នកជិតខាងគេប្រាប់មីង...តែមីងអត់ជឿដល់តាមីងអត់ជឿអញ្ចឹងទៅមីងតាមដានបានដល់មីងតាមដានទៅបានដឹងថាគាត់បានក្បត់...

កៈ គាត់លាក់មីងដល់មីងចេញពីពេទ្យទៀតក៏លាក់អត់ប្រាប់ដែរ។

ខៈ លាក់ញ៉ុមរបូត...ទៅក៏ញ៉ុមនឹកឃើញថាបើមានក៏យកគ្នាទៅក៏ញ៉ុមអត់ថាទេ ខ្ញុំសុខចិត្តរកស៊ីចិញ្ចឹមកូនតែទុកកូនអោយញ៉ុមម៉ោ...!

កៈ ចាំ....ទុកកូនទាំងអស់អោយញ៉ុមម៉ោ!

ខៈ ចាំ...ដល់គេទុកកូនអោយញ៉ុមទៅញ៉ុមក៏ចិញ្ចឹមកូនទៅ គេក៏គេទៅយកប្រពន្ធនោះទៅ...។

កៈ អញ្ចឹងគាត់មានកូនមានចៅតទៀតទៅ?

ខៈ ញ៉ុមអត់ដឹងទេគ្រូញ៉ុមអត់ដឹងទេ!
ដឹងតែគេមានប្រពន្ធមានកូនមានចៅទៀតញ៉ុមអត់ដឹងទេទៅក៏ញ៉ុមរកស៊ីចិញ្ចឹមកូនតាំងតែពីកូនញ៉ុមអាតុដប់ពីរឆ្នាំរហូតដល់ខ្ញុំយកកូនទៅថៃរបូតបានខ្ញុំមកនៅចុងឃ្មៀសនេះបានបីបួនឆ្នាំបិនណេះឯងទៅក៏បានញ៉ុមឈប់ដើរឈប់អីដល់កូនធំកូនក៏រកស៊ីចិញ្ចឹមញ៉ុមវិញទៅសែងត្រីដល់សព្វថ្ងៃនិងទៅ។

កៈ ចាំ...អ៊ុំធ្លាប់នាំកូនទៅថៃដែរអេះអ៊ុំណោះ?

ខៈ ចាំ..ទៅ!

កៈ ទៅធ្វើការនៅនុង?

ខៈ ធ្វើការបេះដំឡូង បេះដំឡូង។

កៈ ដកជំឡុងណោះអុំណោះ?

ខៈ អត់តេសកូនធ្វើការអង្គុយជិព្រាំជំឡុងអោយគេ...

កៈ គេទុកធ្វើម្សៅមីឬក៏?

ខៈ បានមួយខេងមួយពាន់...!

កៈ មួយខេងមិនដឹងប៉ុនណាទេ?

ខៈ ម៉ាខេងយើង មួយខេងប្រហែលប៉ុនៗណោះអ្នាស!

កៈ អ៎...ចាំ...យើងអង្គុយជិព្រាំអោយគេរហូតអញ្ចឹងទៅ...

ខៈ
ចាំ....យើងអង្គុយជិព្រាំអោយគេមួយថ្ងៃចឹងបានប្រហែលហាសិបខេងបានប្រាក់ខ្លះគ្រាន់ចិញ្ចឹមកូនទៅ
ហើយក៏ដល់ពេលកូនធំទៅកូនគេថាម៉ាក់អើយមិនបាច់ទៅណាទេចាំញ៉ុមរកស៊ីចិញ្ចឹមម៉ាក់ឯងវិញក៏របូតតាំងពីពេលនិងម៉ោមីងមិនដែរបានទៅណាទៀតទេ មិនដែរទេ...!

កៈ ចាំ.....អ្នកមីងបានកូន!

ខៈ រហូតដល់មីងធ្លាក់ខ្លួនឈឺទៀតរាល់ថ្ងៃ..

កៈ ចាំ....មីងមានជំងឺជាប់ខ្លួនទៀត!

ខៈ អញ្ចឹងបានថាមីងផ្តាំទាំងអស់គ្នាកុំអោយ កុំអោយធ្វើដូចតម្រាប់មីងទៀត
អ្នកទាំងអស់គ្នាកុំអោយយកតម្រាប់តាមប្តីខ្ញុំដែរធ្វើចំពោះខ្ញុំអោយមើលចេះថែរក្សាកូនចៅកុំអោយដូចជារូបខ្ញុំព្រោះខ្ញុំកំសត់ណាស់រឿងខ្ញុំកំសត់ណាស់(គាត់យំ)។

កៈ
ខ្ញុំអរគុណច្រើនមែនទែនដែលអ្នកមីងបានចែកចាយអំពីក្នុងដួងចិត្តអ្នកមីងខ្ញុំដឹងថាពេលខ្លះយើងសើរើរវាឡើងវិញទៅយើងនឹកឃើញទៀតណោះអ្នកមីងណោះចាំអត់អីទេ

អ្នកមីងវាកន្លងផុតអស់ហើយណោះអ្នកមីងណោះហើយអ្នកមីងបានឆ្លងកាត់វាយ៉ាងល្អទៀតអ្នកមីងបានចិញ្ចឹមកូនៗតាំងពីក្មេងៗរហូតដល់ពួកគាត់ធំមានគ្រួសាររៀងៗខ្លួននេះហើយជាលទ្ធផលរបស់អ្នកមីងដែរអ្នកមីងបានប្រឹងប្រែងមែនទេអ្នកមីង?

ខ៖ មីងនិយាយលេងរួចហើយ(យំ)មីងនិយាយលេងរួចហើយក្មួយ។

ក៖ ចាំ....ថាតើអ្នកមីងមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

ខ៖ ប្រាំមួយនាក់....!

ក៖ ប្រាំមួយនាក់! ណោះអ្នកមីងណោះ? ស្រីប៉ុន្មានប្រុសប៉ុន្មានអ្នកមីង?

ខ៖ ស្រីបួនប្រុសពីរទេអី...ស្រីតាពីរទេ!

ក៖ ស្រីពីរប្រុសបួនវិញ?

ខ៖ ស្រីពីរប្រុសបួន!

ក៖ ឥលូវពួកគាត់នៅទីណាដែរ?

ខ៖ ពួកគាត់នៅឯខាងស្វាយនៅឯប្រាសាទតាក្របី

ក៖ ប្រាសាទតាក្របី...! ចាំ..អញ្ចឹងមានតែអ្នកមីងទេដែរផ្លាស់ប្តូរមកទីនេះ?

ខ៖ និងឯង......!

ក៖ ម្នាក់ឯង.....?

ខ៖ ម្នាក់ឯង......

ក៖ ចុះបងប្អូនឯទៀតគាត់នៅទីនោះទាំងអស់រស់នៅអត់បែកខ្ញែកគ្នាទេ?

ខ៖ អត់ទេ...!

ក៖ ចុះអ៊ុំមានធ្លាប់ដូចជាទៅលេងទៅសួរសុខទុក្ខបងប្អូនអីធ្លាប់ទេ?

ខ៖ មីងអត់មានសមត្ថភាពទៅសួរទេ ព្រោះមីងវាក្រពេក
ក្រដល់កូរ៉េគេធ្វើផ្ទះអោយមិចទៀត អត់មានសមត្ថភាពទៅទេកូន...!
រកតែអង្ករច្រកឆ្នាំងអត់បានផងមីងអត់មានសមត្ថភាពទេក្មួយ!
បើបងប្អូនគេរត់មករកខ្ញុំគេមាន!
បើថាអោយញុំមរត់ទៅរកបងប្អូនញុំមទៅអត់បានទេ...។

ក៖ អញ្ចឹងបងប្អូនអ្នកមីងគាត់ធ្លាប់មកលេងអ្នកមីងដែរ?

ខ៖ អត់...!

ក៖ តែគេធូរធារជាងអ្នកមីង?

ខ៖ ចាំ...!

ក៖ អញ្ចឹងតើអ្នកមីងអាចរៀបរាប់ឈ្មោះពួកគាត់បានទ
ថាបងច្បងនិងឈ្មោះអីហើយបន្ទាប់ៗទៀត?

ខ៖ បង បងញុំមបង្កើតនិងឈ្មោះអឹក...តែដល់ពេលនេះគេហៅគាត់សឿន......

ក៖ ឈ្មោះ សឿន......

ខ៖ ចាំ...សឿនតែដល់ពេលសព្វថ្ងៃគេហៅគាត់ថាឈ្មោះ រុំ.....

ក៖ ឈ្មោះ រុំ......!

ខ៖ ដល់ពេលប្អូនញុំមនៅឯជាយដែនឯណោះវិញគាត់ឈ្មោះឋាន
ប្រពន្ធគាត់និងឈ្មោះ សុខលី...ហើយបើថាប្អូនញុំមមួយទៀត គាត់ឈ្មោះ ជា
ធ្វើទាហ៊ាននៅប្រាសាទតាក្របីប្រពន្ធឈ្មោះ តុត គេតែងហៅមីកាតុតៗ
នៅណោះតែបើអ្នកនៅសៀមរាបឯណោះហៅវាថា ភាព
ប្អូនញុំមមួយទៀតមេម៉ាយដូចគ្នាតែកូនប្រាំពីរនាក់អឹក...ឈ្មោះមីរ៉ែមេម៉ាយតែប្ដីស្លាប់
បានកូនបួសមួយមានប្ដីស្លាប់មេម៉ាយដូចខ្ញុំដែរអញ្ចឹងឯងនិងស្រីបើប្អូនពៅខ្ញុំនោះគាត់

ធ្វើជាទាហ៊ាននៅប្រាសាទតាក្របីកូនបួននាក់ចិញ្ចឹមម្ដាយខ្វាក់មួយជំហៀងមានតែប៊ិន និងឯង....

ក៖ ចាំ....! អញ្ចឹងប្អូនពៅអុំជាអ្នកចិញ្ចឹមម្ដាយ?

ខ៖ ចាំ.....!

ក៖ ចាំ....ដោយសារគាត់មានសមត្ថភាពចិញ្ចឹមជាង!
តែអ្នកមីងបានអត់មានសមត្ថភាពចិញ្ចឹម!

ខ៖
គាត់មានសមត្ថភាពចិញ្ចឹមឬអត់សមត្ថភាពមីងអត់ដឹងទេព្រោះមីងបានចេញម៉ោពីនុង យូរគ្រាន់ហើយព្រោះមីងអត់បានទៅលេងនិងគាត់...

ក៖
ចាំ.....អញ្ចឹងគាត់ក៏នៅជាមួយកូនពៅរហូតដល់គាត់ចាស់បានកូនពៅចិញ្ចឹមម៉ោរហូត ទៅ.....!

ខ៖ ចាំ....!

ក៖ អញ្ចឹងអ្នកមីងជាកូនទីប៉ុន្មាន?

ខ៖ កូនទីពី....!

ក៖ អ្នកមីងជាកូនទីពីក្នុងគ្រួសារ?

ខ៖ ចាំ....!

ក៖ ចុះដូចជាពួកគាត់មានមុខរបរអ្វីរៀងៗខ្លួនអ្នកមីងដឹងទេ?

ខ៖ មីងអត់ដឹងទេក្មួយ!

ក៖ មិនដឹងថាគាត់មានមុខរបរអីទេណោះមីង?

ខ៖ អត់ដឹងទេ!

ក៖ បើថាទីកន្លែងដែលគាត់នៅអាចដឹងខ្លះណោះមីង?
បើថាគាត់ធ្វើមុខរបរអីមីងមិនដឹងទេ?

ខ៖ ចាំ...ពីមុនញ៉ុមអាចដឹង តែឥលូវគាត់ទៅរកមុខរបរអីទៀតមីងអត់ដឹង!

ក៖ កាលពីមុនគាត់ប្រកបរបររកស៊ីអីគេដែរ?

ខ៖
កាលពីដើមមិញគាត់ដើរបេះផ្កាឈូកបេះអីដូចតែញ៉ុមនិងឯងបេះផ្កាស្មោផ្កាអីចិញ្ចឹមកូន
គាត់ប្រពន្ធគាត់និងឯងរហូតឥលូវកូនៗគាត់មានប្ដីមានប្រពន្ធ។

ក៖ ចាំ...!

ខ៖ តែវាគ្រាន់វាគ្រាន់ជាងញ៉ុម
ប៉ុន្តែដល់ពេលសព្វថ្ងៃគេគ្រាន់ហើយគេរៀងគ្រាន់បន្តិចទៅ....មានតែខ្ញុំទេមានជាងគេ
មានមែនទែនមានឡើងមានឡឹងទឹកភ្នែក!

ក៖ មានឡឹងទឹកភ្នែក!ចាំ
ចុះតើជំនាន់របស់អ៊ុំបងប្អូនអ៊ុំអីគាត់រស់នៅសាមគ្គីគ្នាល្អគ្នាល្អទេ?

ខ៖ អត់ដឹង!
អត់ដឹងថាល្អឬមិនល្អសាមគ្គីឬមិនសាមគ្គីគ្នាអីមីងអត់ដឹងទេព្រោះគេនៅឆ្ងាយបើគេមួ
យនៅប្រាសាទតាក្របីទៅប្រាសាទតាមាន់ទៅអីស្វាយឯណោះឯជាយដែនឯគីឡូដប់មួ
យយើងឯណោះមីងអត់ដឹង!

ក៖ ចុះដែលថានៅពីក្មេងអឺណាស់អ៊ុំកាលនៅមួយម៉ែទាំងអស់គ្នា! ?

ខ៖ អត់អីទេ...!

ក៖ ស្រលាញ់គ្នា...

ខ៖ អូយស្រលាញ់គ្នាណាស់!
បងប្អូនញ៉ុមស្រលាញ់គ្នាណាស់មិនចេះឈ្លោះគ្នាទេច្រូងដូចគ្នាអញ្ចឹងអ្វេកអត់ចេះឈ្លោះគ្នាអត់ចេះប្រកែកគ្នា...អត់!
ដល់ពេលគេបានប្ដីបានប្រពន្ធទៅគេបែក....បែកៗអស់ដូចតែកូនមីងអញ្ចឹងណាស់បែកទៅអស់ហើយគេទៅអស់ទៅ...!

ក៖ ចាំ...ចុះអ្នកមីងមានកូនប៉ុន្មាននាក់ដែរ?

ខ៖ ញ៉ុមអូស...?

ក៖ ចាំ...អ្នកមីង!

ខ៖ ខ្ញុំមានកូនដប់ពីរនាក់ ដប់ពីរនាក់តែស្លាប់អស់ប្រាំមួយនាក់
ងាប់អស់ប្រាំមួយនៅប្រាំមួយនៅប្រុសបីស្រីបី....

ក៖ ចុះអ្នក

ដែលស្លាប់ទៅនិងស្រីប៉ុន្មានប្រុសប៉ុន្មាន?

ខ៖ ស្លាប់ស្រីបីប្រុសបី។

ក៖ អញ្ចឹងអ៊ុំស្មើច្រេញម៉ង? ប្រុសប្រាំមួយស្រីប្រាំមួយ?

ខ៖ ចាំ....!

ក៖ និយាយពីឡូយឡើងអ៊ុំ!
អញ្ចឹងតើអ៊ុំអាចប្រាប់បានទេថាកូនរបស់អ៊ុំដែលចែកឋានទៅនិងគាត់ស្លាប់ដោយសារអីដែរ?

ខ៖ ហើម គ្រុន...គ្រុនឈាមហើម
ហើយនេក...ហើយស្មាទោសយើងដើរៗទៅម៉ោពីរត់លេងទៅក្ដៅខ្លាំងទៅអោយញ៉ាំថ្នាំទៅក៏ប្រកាច់

ពេលញាំុថ្នាំទៅនិងក្តៅខ្លួនឈឺក្បាលទៅមីងច្រកថ្នាំប៉ារ៉ាទៅវាប្រកាច់ៗៗៗទៅក៏បញ្ឈរ ភ្នែកទៅក៏បានមួយយប់មួយថ្ងៃទៅក៏ងាប់ បើហើមនោះតាមួយយប់មួយថ្ងៃក៏ងាប់...!

កះ គាត់ហើមដោយសារអី?

ខះ វាហើមដៃហើមជើងវាទៅណាស់!

កះ កាលនៅតូចៗឬក៏ធំហើយ?

ខះ វាធំៗគ្រាន់ហើយវាអាយុប្រាំពីរប្រាំបីឆ្នាំប្រាំបីប្រាំបួនឆ្នាំប្រាំឆ្នាំដប់ឆ្នាំអីទៅណាស់។

កះ ហើមដៃហើមជើងអត់មូលហេតុ?

ខះ
អត់ដឹងមូលហេតុទេងាប់បណ្តោយមានអីព្រឹសៗដូចយើងស្មាទោសដូចយើងមួលកទាអញ្ចឹងម្អាស...!

កះ ចាំ....

ខះ មួលកទាទៅក៏ងាប់បណ្តោយ......អស់ប្រាំមួយកូនស្រីបីប្រុសបី.....

កះ អ៊ុំអាចចាំឈ្មោះពួកគេបានទេ?

ខះ អឺ....កូនអើយចាំមិនបានទេ!

កះ ភ្លេចអស់ហើយណោះអ៊ុំណោះ?

ខះ កូរ៉េគេម៉ោទៀតហើយនិងអែក!

កះ ចាំ....!

ខះ កូរ៉េនិងឯងដែលជួយខ្ញុំ....

កះ ចាំ...អ៊ុំ!

ខ៖
ចាំអត់បានទេក្មួយ...មីងប្រាប់ត្រង់ចាំអត់បានទេមិនដឹងថាឈ្មោះអីឈ្មោះអីខ្លះទេព្រោះមីងសព្វថ្ងៃដូចវង្វេងវង្វាន់....!

ក៖ ចាំ....!

ខ៖ ចាំអត់បានទេ ៗ។

ក៖ តើអ៊ុំអាចរៀបរាប់ឈ្មោះកូនដែលនៅរស់អីណាអ៊ុំថាពួកគាត់មានឈ្មោះអីខ្លះ?

ខ៖ អ្ហឺ...! ចាំអត់បានទេកូន!

ក៖ កូននៅរស់អីណាំអ៊ុំ?

ខ៖ អ៎..កូននៅរស់អ្ហោះ?

ក៖ ចាំ...! គាត់មានឈ្មោះអីដែលទៅ?

ខ៖ ឈ្មោះ...អឺ...រ៉េត! អឺ...សិដ្ឋ! អឺ...ឈ្មោះអឺក...រួន មួយបងគេបង្អស់ ឈ្មោះរួន ហើយរួនមោ ឈ្មោះកូនទីពីឈ្មោះចក់!

ក៖ ចាំ....!

ខ៖ កូនទីបី ឈ្មោះអាថែម...ប្រុស! ហើយកូនទីបួនឈ្មោះមីខៀន...ស្រី កូនទីប្រាំឈ្មោះរិទ្ធី កូនទីប្រាំមួយឈ្មោះ ស្រីមុំពៅគេនិងអស់ អស់ហើយ ប៉ុនតែដល់តែពេលកូនងាប់មីងអត់ចាំទេតែបសួរថ្មីៗមីងចាំតែដល់តាពេលវាច្រើនឆ្នាំទៅមីងអត់ចាំឈ្មោះកូនអស់ទេកូន!

ក៖ ព្រោះអ៊ុំបានហៅកូនតែប៉ុន្មានឆ្នាំនិង!

ខ៖ និងឯងចុះបើបីឆ្នាំបួនឆ្នាំកូនងាប់អ្ហោះ...!

ក៖ ចាំ...

ខ៖ មីងអត់ចាំទេបើថាចាំមីងចាំតែឈ្មោះកូននៅរស់។

ក៖ ចុះម្តាយអ៊ុំស្រីវិញឈ្មោះអីដែរ?

ខ៖ ឈ្មោះ ភ័ណ្ឌ...!

ក៖ ឈ្មោះ ភ័ណ្ឌ....?

ខ៖ ចា៎...! គាត់ឈ្មោះ សិរីសោភ័ណ្ឌ។

ក៖ គាត់អាយុប៉ុន្មានហើយ?

ខ៖ គាត់អាយុប៉ែតសិបហើយ....

ក៖ ប៉ែតសិបហើយ...ណោះអ៊ុំណោះ?

ខ៖ ចា៎....

ក៖ តែគាត់រស់នៅជាមួយកូនពៅ?

ខ៖ រស់នៅជាមួយកូនពៅ! ចា៎.....

ក៖ ចុះឪពុករបសលអ៊ុំស្រីវិញ?

ខ៖ គាត់ខូចហើយ!

ក៖ តែគាត់ឈ្មោះអីគេដែរ?

ខ៖ ឈ្មោះ វិន......

ក៖ វិន.....?

ខ៖ ចា៎....វិន!

ក៖ គាត់ខូចនៅអាយុប៉ុន្មានដែលអ៊ុំ?

ខ៖ កាលគាត់ខូចគាត់អាយុហុកសិបប្រាំបី!

ក៖ អំ...ចាំ!

ខ៖ កាលគាត់ខូចគាត់ខូចនៅចុងស្រុកអាយុហុកសិបប្រាំបី!

ក៖ ចាំ...តែគាត់ស្លាប់ដោយសារអីគេដែរ?

ខ៖ ឈឺ....គាត់មានជំងឺបេះដូងរីក ឪពុកខ្ញុំបេះដូងគាត់រីក គាត់បេះដូងរីកគាត់ខូចតាំពីអាយុហុកសិបប្រាំបី!

ក៖ បេះដូងគាត់រីកយកៗរហូតដល់ស្លាប់បណ្ដោយ?

ខ៖ គាត់ឈឺឡើងពីឆ្នាំ!

ក៖ អូយ...! មិនដឹងថាអានិងគេហៅរោគអីទេអ៊ុំអើយ!

ខ៖ ឪពុកខ្ញុំឈឺពីឆ្នាំហើយឈឺទៅក្ដៅ...តែដើមទ្រូងនាគ...ឈឺក្ដៅ ឈឺក្ដៅទៅ...ដល់តែពេលថាគាត់អស់អាយុផងអីផងមិនថាយ៉ាងមិចមិនដឹងអីមិនដឹងទេណាក្មួយ! ក៏គាត់ខូចប្រហែលម៉ោងបី ម៉ោងបីដប់នាទី...គាត់ខូច!

ក៖ អំ..អំចាំ! គាត់ខូចនៅៗ..?

ខ៖ នៅចុងស្រុកយើងនេះ!

ក៖ អំ....

ខ៖ ចុងស្រុកវត្តអរញ្ញនេះ...

ក៖ គាត់ជាមនុស្សបែបណាដែរទៅអ៊ុំ? ដូចថាតើគាត់ស្លូតឬគាត់កាចឬក៏...?

ខ៖ ទេអត់ទេ....ឪពុកម្ដាយខ្ញុំមិនដែលកាចដាក់ខ្ញុំផង!

ក៖ ស្លូតៗទាំងអស់អ្នោះ?

ខៈ ស្លូតៗទាំងអស់!

កៈ អញ្ចឹងបានជាកូនៗគាត់មិនចេះឈ្លោះគ្នាតាមនិងអ្នាស!
ហើយចុះម្ដាយក៏អញ្ចឹងដែរគាត់ស្លូតដែរ?

ខៈ ម្ដាយខ្ញុំក៏....អឺម្ដាយញ៉ុមអង្គុយមួយថ្ងៃម្ដាយញ៉ុមរុយទុំមិនបក់មាត់ផង!

កៈ អូយ...ដល់ថ្នាក់និងអ៊ុំ! (សើច)ចាំ...ក៏ដូចជា...

ខៈ គាត់ស្លូតដែរ...!

កៈ តើអ៊ុំចាំអំពីថាតើគាត់ធ្លាប់ប្រៀនប្រដៅអ៊ុំថាមិចខ្លះឬក៏អីអញ្ចឹងអីណាស់?

ខៈ អត់!
គាត់មិនដែរប្រៀនប្រដៅខ្ញុំទេប៉ុនតែខ្ញុំបានដឹងខ្លួនឯងព្រោះខ្ញុំជាកូនទីពីរដូចច្នេះខ្ញុំដឹង
ថាអ្វីជាអ្វីដើម្បីចិញ្ចឹមប្អូនចិញ្ចឹមម្ដាយ!

កៈ ចាំ....

ខៈ
គាត់មិនដែរប្រៀនប្រដៅខ្ញុំច្រើនទេព្រោះខ្ញុំដឹងតែរែកត្រីចិញ្ចឹមបងចិញ្ចឹមប្អូនកាលញ៉ុម
នៅលីវវិញមានតែប៉ុននិងឯងព្រោះខ្ញុំកំសត់តាំងពីអើយមកកំសត់តាំងពីឪពុកខ្ញុំគាត់
នៅរស់ម្ដាយខ្ញុំនៅសព្វថ្ងៃខ្ញុំបានចិញ្ចឹមបងចិញ្ចឹមប្អូនរហូត...រហូតដល់ខ្ញុំមានប្ដីហើយក៏
ញ៉ុមនៅតែចិញ្ចឹមរហូតជាប់!

កៈ ចាំ....!

ខៈ អតដែលចេះឈ្លោះគ្នាទេ
ខ្ញុំនឹកឃើញថាកាលណាខ្ញុំឈ្លោះគេទៅខ្ញុំខ្មាសគេជាញ្ញាត្តិដល់ហើយខ្ញុំជាបងគេបងទី
ពីនេះខ្ញុំវាខ្មាសគេខ្ញុំណែនាំបងប្អូនថាអូនអើយកុំឈ្លោះគ្នាបានប៉ុនណាយើងស៊ីប៉ុននិង
តឹកប្អូន...អង្ករកន្លះគីឡូក៏ដោយប៉ុន្នានក៏ដោយនាំគ្នាដាំបបរស៊ីក៏មានដែរ
យ៉ាងណាអត់អោយបងប្អូនឈ្លោះគ្នាទេ....ញ៉ុមមានតែខ្ញុំបងនិងទៅប្រដៅគេតែឪពុក

ម្ដាយខ្ញុំគាត់អត់មានចេះប្រដៅកូនចៅទេ
ប៉ុន្តែកូនចៅអត់ដែលចេះឈ្លោះគ្នាទេ...ព្រោះពួកគាត់ស្លូតៗណាស់ម៉ែឪញ៉ុមអ្ហោះ!

កៈ ចា៎...ចុះគាត់ធ្លាប់និទានប្រាប់អ៊ុំទាក់ទងទៅនិងខ្សែជីវិតគាត់កាលពីក្មេងទេ?

ខៈ អត់ .....

កៈ គាត់អត់ដែលនិយាយទេ.....

ខៈ ចាស់ៗពីដើមគាត់អត់ដែលនិយាយអីផង
លឺតែគាត់និយាយថាពីដើមមិញឪពុកជិះកង់ឈើ...ប៉ុននិង!

កៈ ហ៊ិហ៊ិ...(សើច)
តើកាលអ៊ុំនៅក្មេងអ្នាសឪពុកម្ដាយរបស់អ៊ុំគាត់ធូរធារឬក៏គាត់ក្រលំបាកតាំងពី

អ៊ុំនៅក្មេងម៉ោ?

ខៈ គាត់មាន......

កៈ គាត់ធូរធារដែរ?

ខៈ ចា៎ស...!

កៈ គាត់មានមុខរបរអីគេដែរបានជាគាត់ធូរធា?

ខៈ គាត់ស្រែ....! ស្រែចំការទៅគោគាត់រាប់រយរាប់ពាន់ក្បាលអ្ហោះ!

កៈ ចា៎....

ខៈ គាត់មាន ដល់តែពេលគាត់មានកូនម៉ោគាត់ធ្លាក់ខ្លួនក្រត្រឹមញ៉ុម
ត្រឹមញ៉ុមនិងចោរប្លន់គាត់ផងអីផង....

កៈ អូយ...ចោរប្លន់គាត់ទៀយ?

ខ៖ ចាំ...ចោរប្លន់ពីចេិតសិបប្រាំបួនអស់....អស់គោអស់ក្របីទៅគាត់ធ្លាក់ខ្លួន ធ្លាក់ខ្លួនត្រឹមញ៉ុមនិងឯង...បានញ៉ុមចេះរកស៊ីចិញ្ចឹមបងប្អូនញ៉ុម(សើច)

ក៖ អញ្ចឹងគឺដោយសារតែអ៊ុំធ្លាប់ធ្វើបែបនិងតាំងតែពីនៅក្មេងហើយ អញ្ចឹងបានជាអ៊ុំមានកូនដល់ទៅដប់ពីនាក់តែអ៊ុំអាចចិញ្ចឹមរស់បាន!

ខ៖ ចាំ...ចាំ!

ក៖ ដោយសារអ៊ុំធ្លាប់ធ្វើអីណាំអ៊ុំ?

ខ៖ ចាំ....! ធ្លាប់!

ក៖ ចុះយាយតាខាងម្តាយវិញតើអ៊ុំចាំទេថាគាត់ឈ្មោះអីគេដែរ?

ខ៖ អត់! អត់...ចាំទេក្មួយ...!

ក៖ អូ...អត់ចាំទេ...?

ខ៖ អត់...!

ក៖ អត់បានកើតទាន់ហើយក៏មិនបានលឺឪពុកម្តាយនិយាយអ្វេណោះអ៊ុំណោះ?

ខ៖ កើតទាន់ប៉ុន្តែគាត់អត់និយាយអីផង!

ក៖ ចុះឈ្មោះរបស់គាត់អ៊ុំចាំទេ?

ខ៖ អត់...!

ក៖ អត់ដែរ...?

ខ៖ អត់ទេក្មួយ។

ក៖ ចុះចំណែកឯយាយតាខាងឪពុកក៏អត់ដែរ?

ខ៖ អត់! ...

កៈ អូ....ដាច់ខ្សែរយៈពិទតែម្ដង...?

ខៈ ដាច់...!

កៈ ដាច់បណ្ដោយ...?

ខៈ ចាំអត់ចាំទេ។

កៈ ចុះតើអ៊ុំមានសាច់ញ្ញាត្តិអីដែលនៅឯក្រៅប្រទេសទេ?

ខៈ បើថារឿងសាច់ញ្ញាត្តិនៅក្រៅប្រទេសមាន...ប៉ុន្តែម៉ែឪខ្ញុំជីដូនជីតាខ្ញុំអត់អោយរាប់!

កៈ មិចចឹងទីអ៊ុំ?

ខៈ គាត់ថាអត់អោយទាក់ទង...ទៅញ៉ុមភ្លេចឈ្មោះអស់ហើយ!

កៈ អ្នកណាគេដែលទៅនុងអ៊ុំដឹងថាសាច់ញ្ញាត្តិខាងណាទេ?

ខៈ
ញ៉ុមស្គាល់តែប្អូនធមិញ៉ុមអឺស្គាល់តែនេក.តែនេះទេឈ្មោះប្អូនញ៉ុមនេកមិនដឹងថាប្អូនមិនដឹងថាបងទេពីចិតសិបប្រាំបួនគាត់ទៅនៅខាវដាងទៅ...គាត់ឈ្មោះតាសំណាងៗ...អ៊ុំឱក អ៊ុំម៉ាន អ៊ុំម៉ែ...ស្គាល់តែប៉ុននិងឯងតែកូនគាត់ឈ្មោះមី...មីស្អីទៀត...ញ៉ុមភ្លេច!

កៈ ចាំ...គេនៅប្រទេសណាដែរ?

ខៈ ថានៅប្រទេសស្អីតេសម៉ារឺស៊ីអីតេស...

កៈ ម៉ាឡេស៊ី...?

ខៈ និងហើយប្រទេស ម៉ាឡេស៊ីអីតេស....!

ខៈ
ហើគាត់អត់បានដឹងថាឪពុកមាគាត់នៅឯណេះស្លាប់ទេគាត់អត់ដឹងទេអត់ដឹងថាឈ្មោះឪពុកមាឈ្មោះវ៉ាន់ផងវិនផងគាត់អត់ដឹងទេអត់ដឹងអង្កាលឪពុកមាគាតស្លាប់ទេ

ឈ្មោះសំណាងនិងប្រុសនៅប្រទេសក្រៅកាលបែកពីញ៉ុមកាលទៅពីញ៉ុមនិងតាំងពីគាត់អាយុបីបួនឆ្នាំប្រាំពីរប្រាំបីឆ្នាំអ្ហោះប៉ុនមិនដឹងថាគាត់បងញ៉ុមឬក៏ប្អូនញ៉ុមញ៉ុមអត់ដឹងដែលឺថាសព្វថ្ងៃលឺថាបានប្រពន្ធបារាំង....

កៈ ចាំ....!

ខៈ លឺដំណឹងមកវិញ លឺដំណឹងពីបាត់ដំបងមកវិញ ថាគាត់បានប្រពន្ធបារាំងតែបងប្អូនញ៉ុមម៉ែឪញ៉ុមគាត់ថាកូនអើយគេមានមិនបាច់រាប់គេទេ...

កៈ អញ្ចឹងអ្ហោះ...!

ខៈ ព្រោះថាគេអត់ដឹងថាញ៉ុមរស់នៅសៀមរាប...

កៈ ចាំ....!

ខៈ គាត់អត់ដឹង! មាន...ញ៉ុមស្គាល់តែអ៊ុំឱក អ៊ុំម៉ាន អ៊ុំមៃតែមិនដឹងថាគាត់ងាប់មិនដឹងថាគាត់រស់ញ៉ុមអត់ដឹងទេ អត់ដឹងទេ!

កៈ ចាំ...តែអ៊ុំ...អញ្ចឹងអ៊ុំមានសាច់ញ្ញាត្តិនៅក្រៅប្រទេសច្រើន?

ខៈ ច្រើន...ប៉ុន!

កៈ អ៊ុំអត់សួរបានរាប់?

ខៈ ចាំ...អត់សួរ...អត់ដែលបានរាប់ទេ!

កៈ ចាំ...!

ខៈ អត់ដឹង! ព្រោះបែកគ្នាតាំងពីចិតសិបប្រាំបួនគេដឹកគាត់ទៅយូរឆ្នាំហើយមិនដឹងថាកាលដឹងទៅនិងពីឆ្នាំប៉ុន្មានញ៉ុមអត់ដឹងទេកាលនិងញ៉ុមទៅនៅឯនេក...ខាវដាងអ្ហោះ ទៅនៅខាងខាវដាងទៅញ៉ុមអត់ដឹង!

ថាគាត់ទៅពីឆ្នាំប៉ុន្មានញ៉ុមអត់ដឹងទេកាលញ៉ុមនៅនេះនៅធំជាងមីអូនឯងញ៉ុមមិនដឹង អាយុប៉ុន្មានញ៉ុមអត់ដឹងដែរ កាលអាសំណាង
សំណាងឈ្មោះប្រុសនិងអ្នាំសគាត់ទៅអាយុបួនដប់ឆ្នាំប្រហែលនិងឯង
គាត់មកសួររកញ៉ុមនៅបាត់ដំបងប៉ុន្មានដងហើយប៉ុន្តែបងប្អូនគេថាមិនដឹងថាឈ្មោះវ៉ាន់និងមិនដឹងនៅឯណា....គេអត់ដឹងគេអត់ប្រាប់ងាបងប្អូននិងនៅសៀមរាបគាត់អត់ដឹងទេ សៀមរាបភ្នំក្រោមចុងឃ្នៀសនេះគាត់អត់ដឹងទេ ទៅរហូតដល់ឪពុកខ្ញូមស្លាប់ទៀត!

ក៖ អញ្ចឹងអ៊ុំបានរៀនទេអ៊ុំ?

ខ៖ អឺស....អក្សរមួយអង្គមិនចេះផង!

ក៖ អត់បានចូលសាលាសោះម៉ងអ្ហោះអ៊ុំ?

ខ៖ អត់...!

ក៖ អញ្ចឹងសរសេរអក្សរខ្មែរអានអក្សរខ្មែរគឺអត់កើតម៉ងអោះអ៊ុំ?

ខ៖ អត់...!

ក៖ ចុះភាសាអីផ្សេងក៏អ៊ុំអត់ចេះដែរ?

ខ៖ អត់....!

ក៖ គឺអ៊ុំដឹងតែថារកមុខរបរអីចិញ្ចឹមប្អូនតៗហើយនិងចិញ្ចឹមម៉ែ!

ខ៖ ចិញ្ចឹមតម៉ោរហូត...! ចិញ្ចឹមម៉ែបងប្អូនតរហូតអត់បានចូលសាលាទេ!

ក៖ ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំមានការផ្លាស់ប្តូរហើយឬនអ៊ុំ?
ដូចថាកាលពីក្មេងរៀងធូរបន្តិចទៅហើយតលូវវារៀងពិបាកជាងមុនឬក៏ពីមុនពិបាកតលូវធូរធារជាងមុន?

ខ៖
នៅពីក្មេងគ្រាន់ធូរតែសព្វថ្ងៃពិបាកៗមែនទែនអឺណាំសពិបាករកតែអ្វីមកប្រៀបធៀបពុំ

បាន
ពិបាកឡើងទឹកភ្នែកហូរទៅឡើងលែងចង់និយាយឡើងលែងចង់យំទៅទៀតទៅហើយព្រោះយំអត់ចេញ....!

កៈ
ចាំ...អ៊ុឥលូវយើងបង្វែអារម្មណ៍វិញម្ដងតើមុខម្ហូបដែលអ៊ុំចូលចិត្តវិញតើអ៊ុំចូលចិត្តមុខម្ហូបអីគេដែរ?

ខៈ អីក៏បានដែលកូន!

កៈ ដូចថាអ្នកខ្លះគេចូលចិត្តសម្លរអីអញ្ចឹងអីណាស់អ៊ុំ?

ខៈ សម្លរម្ជូរគ្រឿង សម្លរម្ជូរព្រលិតអីបានអ៊ុំចូលចិត្ត!

កៈ អ៊ុំចូលចិត្តពពួកសម្លរម្ជូរៗអ៊ុំហូបអោយតាជូរៗមាត់អីណោះអ៊ុំណោះ?

ខៈ ចាំ....អោយតែជូរៗមាត់!

កៈ អញ្ចឹងតើអ៊ុំចូលចិត្តម្ជូរទេ ម្ជូរយើងអ្នាំសដូចជាម្ជូរស្វាយខ្ចីអីអ្នាស?

ខៈ ម្ជូរស្វាយអ្ហោះ...? ដាក់មើសមួយគីឡូអស់ឥលូវ(សើច)

កៈ ចាំ....ដូចថាស្វាយច្រលក់អំបិលម្ទេសអីណោះអ៊ុំ?

ខៈ អំបិលម្ទេសអីទឹកត្រី!

កៈ ទឹកត្រី...ៗស្ករយើងនេះ?

ខៈ ទឹកត្រីស្ករមួយគីឡូអស់ឥលូវហើយ(សើច)

កៈ ចាំ...ដាក់ម្ទេសតិចៗម៉ោទំណាងអ៊ុំចូលចិត្តណាស់!
អ៊ុំហេងស៊យពេលអ៊ុំចាញ់កូនមួយញ៉ាំដល់ហើយមើលទៅម្ជូរ?

ខៈ អ៊ុំញ៉ាំតែស្វាយម្ជូរយើងនិងឯង្ហានញ៉ាំអីផ្សេងតេស!

កៈ (សើច) ចុះចំរៀងវិញតើអ៊ុំចូលចិត្តស្តាប់បទចំរៀងមួយណាដែរ?

ខៈ
អូ...កូនអើយបើថាចំរៀងវិញអ៊ុំចលចិត្តស្តាប់តែបទពីដើមទេកូនអើប្រោះបទសព្វថ្ងៃមីងអត់ចេះស្តាប់...! អោយតែ សិនស៊ីសមុទ្រមីងស្តាប់ទាំងអស់មិនថាចំរៀងអី...អោយតែសិនស៊ីសមុទ្រមីងស្តាប់បានទាំងអស់ស្តាប់ទាំងអស់តែក្មេងសព្វថ្ងៃមីងយកសំឡីញ៉ុកត្រចៀកអត់ចេះស្តាប់...!

កៈ (សើច) អត់ចេះស្តាប់ ! ព្រោះបទពៅដើមអន្លង់អន្លូចណាស់...!

ខៈ ចាំ...នោះឯង! ចេះស្តាប់បទអីអោយតែបទពីដើមមីងស្តាប់បានទាំងអស់!

កៈ អូ....ចាំ!
អញ្ចឹងដូចជានៅក្នុងគ្រួសារអ្នកមីងតើមានអ្នកណាដែលថាចេះខាងសិល្បៈដូចថាចេះច្រៀងចេះអាយ៉ៃចេះឧបករណ៍ភ្លេងខ្មែរអីមានទេ?

ខៈ អត់....!

កៈ អត់មានទេណោះអ៊ុំ?

ខៈ អត់ៗៗ...អត់មានទាំងអស់ព្រោះបងប្អូនខ្ញុំគ្មានអាណាចេះអក្សរទេ
ចេះតែអាពៅគេមួយ...!

កៈ
អូ...ចាំ...ឥលូវចង់អោយអ៊ុំស្រម៉ៃថាតើកាលពីអ៊ុំនៅក្មេងអ្នាំសតើស្ថានភាពផ្ទះរបស់អ៊ុំអ្នាំសវាមានលក្ខណៈបែបណាដែរ?វាតូចវាធំឬសង់ពីអីអញ្ចឹងអ្នាំស?

ខៈ ផ្ទះពីសង្គមចាស់មិញអោះ?

កៈ ចាំ...!

ខៈ អ៊ូ....ធំណាំសដំរីចូលអាទ្បុងអ្ហោះ
ធំជាងផ្ទះនេះពីរតអ្ហក..ពីសង្គមមិញអ្ហោះ....កាលម៉ែឪញ៉ុមនៅរស់យាយតាខ្ញុំនៅរស់ផ្ទះ

គាត់ធំហើយខ្ពស់អ្នាំសមិនដឹងថាប៉ុន្មានខ្នងញ៉ុមអត់ដឹងទេប៉ុន្តែបើបានងើយមើលគឺដឹងថាផ្ទះយាយញុមពុកញ៉ុមធំ...ដឹងតែប៉ិននិងឯងប៉ុន្តែមិនដឹងថាប៉ុន្មានខ្នងញ៉ុមអត់ដឹង ...!

កៈ ចាំ.....!

ខៈ អត់ដឹង...!

កៈ អញ្ចឹងកាលនិងធូរធារច្រើន...!

ខៈ ចាំ...ធូរធារស្រែរាប់រយហិចតា..

កៈ ផ្ទះនៅកន្លែងដែលអ៊ុំកើតនិងឈ្មោះអ៊ុំ?

ខៈ និងឯង...!

កៈ តែឥលូវផ្ទះនិងនៅនុងទៀតអត់?

ខៈ អឺ....បងប្អូនគេយកអស់ហើយ ....

កៈ ចែកអ្នំអ៊ុំ...?

ខៈ កាលជំនាន់អាពត គេទាញយកអស់ហើយ!

កៈ ស្មានតែអ៊ុំស្រីអ៊ុំប្រុសគាត់ចែក!

ខៈ អត់ទេ...គេយករបស់គាត់តាំងពីជំនាន់អាពត...

កៈ ពេលបែកមកវិញនិងណោះអ៊ុំណា?

ខៈ ចាំ...គេយកអស់ហើយគ្មានអីសល់ទេ!

កៈ

ចាំ..ចុះដូចជាជំនាញរបស់អ៊ុំស្រីដែលអ៊ុំស្រីអាចធ្វើបានដូចថាតីឪពុកម្ដាយម៉ោមាន...ទេ? ដូចថាធ្វើផ្ដៅធ្វើកន្ទេលធ្វើអន្រីងអីអញ្ចឹងអីណាំសតើអ៊ុំមានចេះធ្វើអីមួយទេ?

ខ៖ ចេះ..! អន្រ្ទឹងចេះធ្វើកន្ទេលមីងចេះ កន្ទេលចាក់អាកន្ទេលអី..

ក មីងចេះច្រើនណាស់នាគ...!

ខ៖ អន្រ្ទឹងមីងចេះប៉ុន្តែភ្នែកសព្វថ្ងៃមីងងងឹតហើយ....អន្រ្ទឹងមីងចេះ
កន្ទេលមីងចេះធ្បាញ ហើយអាៗអាកំប៉ោកនេះក៏មីងចេះធ្វើកន្ទេល
អាកំប៉ោកនិងធ្វើជាបោះពុម្ភធ្វើជានេក..កាបូបក៏មីងចេះ
ហើយស្រោមខ្នើយមីងប៉ាក់មីងចេះ
ហើយខោអាវកូនក្មេងបើចាក់ម្ជុលមួយម្ជុលពីរមីងចេះតែសព្វថ្ងៃមីងងងឹតទៅមីងមើល
អត់ឃើញទេ!

កៈ តែពីមុនមីងធ្លាប់ធ្វើវាលក់ទេ?

ខ៖ ធ្វើលក់...!
កែបកង់កែបអីស្រោមដៃកង់ស្រោមដៃអី...អឺកែបកង់ពីដើមមិញអញ្ចេះមីងចេះចាក់ចេះ
ធ្វើអីទាំងអស់...ចេះភ្នែកភ្លឺ...ថាចេះធ្វើទាំងអស់ម៉ាសព្វកន្ទេលក៏មីងចេះធ្បាញម៉ាសព្វ
តែភ្នែកសព្វថ្ងៃបើសម្លឹងទៅ...ដូចយើងរោសគ្រាប់ភ្នែកស្រវាំងអស់ហើយមើលអត់ឃើ
ញ....

ក៖ ចុះអ៊ុំញ៉ុមស្គាល់អ៊ុំស្រីម្នាក់គាត់ឈ្មោះយាយយ៉ានៗអ្ហោះ...!

ខ៖ យាយយ៉ានណា៎?

ក៖ យាយយ៉ានអ៊ុំស្គាល់ដេស?

ខ៖ យាយយ៉ាននេះអ្ហោះ?

ក៖
អ្ហ៎....មិនដឹងយាយយ៉ានណា៎ទេតែគាត់អ្នកដើរកត់ស្រង់ឈ្មោះអ្នកដៃរចង់ទៅធ្វើភ្នែក!

ខ៖ អ៎...យាយយានស្គាលហើយនៅនេះឯង...!

ក៖ គាត់នៅជិតនេះដែរអ្ហេសអ៊ុំ?

ខ៖ និងហើយគាត់នៅតានេះដែរគាត់ហៅគេអោយទៅបកភ្នែកនៅបាត់ដំបង!

ក៖ ចាំ....ចុះអ៊ុំគិតមិចដែរ អ៊ុំគិតថាគម្រោងនិងទៅឬក៏អត់?

ខ៖ បកភ្នកបកអីអ្ហោះ?

ក៖ ចាំ...!

ខ៖ កូនម្តាយគ្មានលុយទេ!

ក៖ គាត់ថាអត់អស់លុយទេអ៊ុំ គាត់ថាជិះឡានទៅអស់ពីរម៉ឺន...!

ខ៖
ជិះឡាន...និងឯងអស់ពីរម៉ឺននិងវាមិនបានសន្សំទៅណាស់អ៊ុំសន្សំមួយពាន់មួយថ្ងៃក៏បាន....

ខ៖ មួយពាន់...! ចុះបើខ្លួនកំពុងមានវិបត្តិទៅទៀតនោះ មួយាន់ឯណាំកូនអើយ!

ក៖ មួយពាន់អត់មានទៀតណោះអ៊ុំណោះ?

ខ៖ ថាគិតឡើងស្តមខ្លួនហើយ!

ក៖ ចុះអ៊ុំសព្វថ្ងៃប្រកបមុខរបរអីគេដែរ ?

ខ៖ អត់បានរកីទេ...!

ក៖ មានតែកូនគាត់ទៅលើកត្រី!

ខ៖ មានតែម្នាក់និងឯង!

ក៖
ហើយយកលុយពីលើកត្រីអោយគេនិងទៅយកម៉ោចិញ្ចឹមគ្រួសារទិញម្ហូបទិញអីអ្ហោះណោះអ៊ុំណោះ?

ខ៖ និងហើយ..!

ក៖ ចុះថ្លៃទឹកថ្លៃភ្លើងអីមានត្រូវបង់អោយគេទេ?

ខ៖ អត់ទេមានបានប្រើភ្លើងផងអុចតែចង្កៀង!

ក៖ ទូរទ

ស្សន៍ក៏អត់មានមើល

ដែរ?

ខ៖ អូទេ....នេសមើលទៅ! បើកអោយមើលទៀត!

ក៖ បើកអោយមើលទៀត! ចាំ...

ខ៖ នេះមើលអឺកបើមាន នោះអុចចង្កៀងនោះ ប្រាំរយអុចបីយប់អ្ហោះ!

ក៖ តែថ្លៃដីៗគេយកទេអ៊ុំ?

ខ៖ ថ្លៃដីអ្ហោះ...?
បើយើងលើកខែវស្សាដាក់កន្លែងទាហ៊ានគេយកប្រាំម៉ឺនហើយមីងឯងនេះវាអត់មាន
អត់មានដាក់តាមចិញ្ចើមថ្នល់គេដីភូមិគេនាគដាក់តាមចិញ្ចើមថ្នល់គេនាគ!

ក៖ អញ្ចឹងយើងដាក់នៅនិងគេអត់យកលុយទេ?

ខ៖ គេអត់យកលុយទេ....ញ៉ុមវាមានពេកផ្ទះថ្មពេកទៅគេអត់យក គេអត់យកទេ!

ក៖ ចាំ....!
ចុះអ៊ុំធ្លាប់មានក្តីស្រម៉ៃចង់បានអីទេអ៊ុំដូចថាក្តីស្រម៉ៃក្នុងចិត្តអ៊ុំតែងពីក្មេងមានបំណងច
ង់ធ្វើគ្រូបង្រៀនចង់ធ្វើជាគ្រូពេទ្យអីអញ្ចឹងអ្នាំស?

ខ៖ អូ...! ចង់ធ្វើគ្រូឯណាទេបើអត់ចេះអក្សរ...!

កៈ មិនដែលស្រម៉ៃចង់បានអីទេណោះអ៊ុំណោះ?

ខៈ អត់ផង...!

កៈ អត់មានទេណោះ?

ខៈ ចាំ.....!

កៈ ដូចថាយើងអត់បានរៀនទៅអត់មានក្ដីស្រមៃដែរ?

ខៈ អត់បានរៀន! អត់ អត់មានបានរៀនអត់បានអីអត់ចង់ស្រម៉ៃថាចង់ចេះស្អីចេះស្អីអត់អោយតែចិញ្ចឹមកូនរស់ អោយតែបានចិញ្ចឹមកូនរស់ បានព្រឹកហូបព្រឹកបានល្ងាចហូបល្ងាច!

កៈ
អូចាំ....ហើយដូចជាចុះតើអ៊ុំមានពាក្យពេចន៍អ្វីដើម្បីផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយទេ?

ខៈ
អ៎....មានសូមផ្ដាំកូនចៅជំនាន់ក្រោយកុំអោយធ្វើតម្រាប់តាមខ្ញុំអោយកូនចៅនិងរៀនអោយចេះអក្សរកុំអោយដូចខ្ញុំល្ងង់ល្ងិតអោយរកអនាគតកុំអោយដូចខ្ញុំដែលខ្ញុំក្រីក្រណាស់ព្រោះអត់មានអីទេអោយកូនចៅជំនាន់ក្រោយនិងអោយរកស៊ីអោយមានបានអោយត្រជាក់អោយត្រជុំកុំអោយដូចជារូបខ្ញុំ
ព្រោះខ្ញុំអត់ចេះអក្សរទេបើកូនចៅជំនាន់ក្រោយអោយខំរៀនអោយកុំសូត្រអោយបានចេះអោយដឹងកុំអោយដូចជារូបខ្ញុំចិញ្ចឹមកូនដប់ពីរហើយពិបេកពិបាកវេទនាសព្វគ្រប់សព្វថ្ងៃនៅតែមួយរយខ្មែរនៅនិងខ្លួនបើងាប់ទៅរកតែមួយរយខ្មែបង់និងវត្តគ្មានទេសព្វថ្ងៃនេះខ្ញុំផ្ដែផ្ដាំបានតែប៉ុននិងឯង.....!

កៈ
អរគុណាច្រើនហើយណាអ៊ុំដែលអ៊ុំបានចំណាយពេលវេលាមួយដែលថាអ៊ុំអាចចែកចាយនូវអ៊ីអំពីខ្សែជីវិតរបស់អ៊ុំមានទាំងរឿងស្វាមីអាពាហ៍ពិពាហ៍មានទាំងរឿងចិញ្ចឹមកូនចិញ្ចឹមក្រុមគ្រួសារធ្លាប់ធ្វើការងារគ្រប់សព្វទាំងអស់ចាំ...ហើយខ្ញុំដឹងថានេះដោយសាតែ

អ៊ុំជាស្ត្រីរឹងមាំម្នាក់ហើយណាស់អ៊ុំបើអ៊ុំជាស្ត្រីទន់ខ្សោយវិញមានបញ្ហាបែបនេះគេសម្លាប់ខ្លួនបាត់ហើយអ៊ុំ!
កូនក៏ច្រើនហើយអឹក...លុយក៏គ្មានចិញ្ចឹមកូនទៀតមិនដឹងថាមានមុខរបរអីអោយអាចចិញ្ចឹមដែលថាអត់ពីប្តីទៅភ្លាមៗអីណាំអ៊ុំកូនក៏ទើបនិងកើតហើយទៀតអញ្ចឹងវាពិបាកសព្វគ្រប់ហើយតែអ៊ុំអាចឆ្លងបានអស្ចារ្យមែនទែនអ៊ុំជាស្ត្រីម្នាក់ដែរថាជាគំរូដល់ញ៉ុមអីណាអ៊ុំអញ្ចឹងញ៉ុមដឹងថាអ្នកណាដែលបានលឺសម្លេងរបស់អ៊ុំទាំងអស់នេះគឺពួកគេយកគំរូល្អៗតាមអ៊ុំច្រើនដែលជាគំរូស្ត្រីរឹងមាំម្នាក់និងអ្នាស!

ខ៖ ចាំ.....!

ក៖
ហើយគាត់ក៏និងព្យាយាមដើម្បីចេះជំនាញច្រើនដូចជាអ៊ុំដើម្បីងាយស្រួលបើពួកាត់ជួបបញ្ហាដូចជាអ៊ុំអញ្ចឹងគាត់អាចដោះស្រាយបានដូចអ៊ុំអញ្ចឹង!

ខ៖ ចាំ.....!

ក៖
ហើយពួកយើងសូមជូនពរអោយអ៊ុំមានសុខភាពល្អហើយដូចជាមានកំលាំងច្រើនឡើងវិញដើម្បីបន្តរស់នៅយូរអង្វែងនៅមើលឃើញចៅមើលក្មួយអ៊ុំតទៅទៀតហើយនៅមើលកូនអ៊ុំកូនរបស់ពួកគាត់តទៀតនិយាយទៅអនាគតរបស់គាត់យើងមើលអត់ឃើញទេណាអ៊ុំថាគាត់និងរីកចំរើនឬក៏និងដុះរីកធំធាត់យ៉ាងណាំទេអញ្ចឹងសូមជូនពរអ៊ុំមានអាយុវែងដើម្បីចាំមើលអនាគតពួកគាត់ព្រោះថាគោលបំណងរបស់អ៊ុំគឺចង់ឃើញអនាគតរបស់ពួកគាត់អញ្ចឹងសូមអ៊ុំនៅតែបន្តមានសុខភាពល្អរស់នៅមានអាយុវែងសូមអោយគ្រួសាររបស់អ៊ុំនិងមានជំនួយគេចុះមកជួយច្រើនហើយមានភាពរីកចំរើនក្នុងគ្រួសារអញ្ចឹងអីណាំអ៊ុំ?

ខ៖ ចាំ.....!

ក៖
ហើយពួកយើងមានតែប៉ុននិងហើយពួកយើងសុំការអនុញ្ញាតពីអ៊ុំម្តងទៀតដើម្បីដាក់សំលេងរបស់អ៊ុំនិងរូបថតរបស់អ៊ុំចូលទៅក្នុងគេហទំព័ររបស់ពួកយើងអ៊ុំយល់ព្រមទេ….!

ខ៖ បានតាសកូន!

ក៖
ចាំ…អរគុណច្រើនអ៊ុំហើយពួកយើងមានតែប៉ុននិងហើយសូមគោរពជំរាបលាអ៊ុំស្រី….!

ខ៖ ចាំ..ចាំៗកូនចាំ!